# ខ្លឹមសារសង្ខេប

# សាលដីកាព្រហ្មទណ្ឌ តុលាការកំពូល លេខ ៥ (១១ ខែ មករា ឆ្នាំ ២០០៦)

http://www.measboralaws.com/detail/1074

ពាក្យគន្លឹះ៖ រំលោភសេពសន្ថវៈ សម្រេចដល់ទីជំរៅ

អំពើកើតនៅក្នុងខេត្តបន្ទាយមានជ័យ ក្នុងឆ្នាំ ២០០០។ តុលាការខេត្តបន្ទាយមានជ័យ បានកាត់ដាក់ទោស ៧ ឆ្នាំ និងជំងឺចិត្ត ២ លានរៀន ពីបទរំលោភសេពសន្ថវៈ។ សាលាឧទ្ធរណ៍ សម្រេចកែបទល្មើស ទៅជា បទប៉ុនប៉ងរំលោភ ដាក់ទោសពន្ធនាគារ ៥ ឆ្នាំ នឹងសំណង ចំនួន ១ លាន ដោយសំអាងថា មិនសម្រេចដល់ទីជំរៅ (មេធាវីជនជាប់ចោទលើកបញ្ហានេះដែរ)។ តុលាការកំពូលបាន សំអាងថា៖ *យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចកែប្រែបទចោទប្រកាន់ លើជនជាប់ចោទទៅជាបទប៉ុនប៉ងរំលោភសេពសន្ថវៈដោយសំអាងហេតុថាតាមវិញ្ញាបនបត្រលេខ១១៧៣ ចុះថ្ងៃទី២៣-១១-២០០០ របស់មន្ទីរពេទ្យបង្អែកស្រុកមង្គលបុរី បានសន្និដ្ឋានថា ការរំលោភសេពសន្ថវៈមិនមានភាពស៊ីជំរៅនោះ ជាការភ័ន្តច្រឡំ ពីព្រោះថាថ្វីបើការរំលោភសេពសន្ថវៈ ដែលមិនមានភាពស៊ីជំរៅក៏ពិតមែន ប៉ុន្តែជនល្មើសបានសម្រេចនូវគោលបំណងរបស់ខ្លួនហើយ។*

តុលាការកំពូល សម្រេច តម្កល់សាលដីកា តែប្តូរពីបទប៉ុនប៉ង ទៅបទរំលោភសេពសន្ថវៈ។

<u>កំណត់សំគាល់</u>៖ ១. នេះបង្ហាញថា មានចំណុចខ្វែងបញ្ហាច្បាប់ពាក់ព័ន្ធនឹងធាតុផ្សំសម្ភារៈ។ តើទាមទារដល់ទីជំរៅដែរឬទេ?។ តុលាការកំពូល ហាក់មិនតម្រូវ។ អ្វីសំខាន់ទំនងជាថា ជនល្មើសសម្រេចបំណងរបស់គាត់ឬទៅ? តាមច្បាប់ បទល្មើសបានសម្រេច និងប៉ុនប៉ង មានទោសដូចគ្នា។ ក៏ប៉ុន្តែ តាមសាលដីកានេះបទប៉ុនប៉ងទទួលទោសស្រាលជាង។ សម្រាប់បទប៉ុនប៉ង សូមចូលទៅកាន់គេហទំព័រ http://www.measboralaws.com/detail/1067សម្រាប់បទរំលោភសេពសន្ថវៈ(បទពុម្ពនាពេលខាងមុខ)សូមមើល https://www.bakc.org.kh/index.php/km/ ។